មាត្រា ២ .- ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ផ្គត់ផ្គង់ ឯកសណ្ឋាន និង គ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ កងជីវពល ឆ្នាំ ២០០១ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

===

# អនុក្រឹត្យលេខ ៥១ អនក្រ.បក

# ស្តីពីការធ្វើវិសោធនកម្មលើ

# អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧

# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខា ធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា តែមួយ .-**

មាត្រា ៣ ៦ ១១ ១២ ១៣ ១៤ ១៥ ១៦ ១៧ ១៨ ១៩ ២០ ២១ ២២ ២៣ និង ២៤ ក្នុងជំពូក ២ ៤ ៥ ៦ ៧ ៨ និង ៩ នៃអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានកែប្រែ និងបន្ថែម ដូចតទៅ :

## ជំពូក ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ៣.- ថ្មី**

ក្រសួងអភិវឌ្ឍន៍ជនបទមានមុខងារ និងភារកិច្ចដូចតទៅ :

-កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ជនបទ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

-លើកទិសដៅ ផែនការរយៈពេលខ្លី មធ្យម និងវែង លើការងារអភិវឌ្ឍន៍ជនបទដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជារាស្ត្រជនបទទូទៅដោយរួមបញ្ចូលទាំងជនជាតិភាគតិចក្នុងព្រះរាជាណាចក្រកម្ពុជា អោយកាន់តែល្អប្រសើរឡើង កាត់បន្ថយជាបណ្ដើរៗនូវភាពក្រីក្រ និងភាពខុសគ្នារវាងអ្នកជនបទ និងអ្នកទីក្រុង ។

-ចូលរួមក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដោយគិតសកម្មភាពការងារត្រឹមថ្នាក់គ្រួសារ ភូមិ និងឃុំ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

-សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យ ពត៌មាន ស្ថិតិ អំពីស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទាំងតំបន់ភ្នំ តំបន់ខ្ពង់រាប និងតំបន់វាលរាប ។

-អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រី បុគ្គលិករាជការរបស់ក្រសួង ។

-រៀបចំបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ភូមិភាគដល់ប្រជារាស្ត្រជនបទតាមការចាំបាច់ និងតាមលទ្ធភាពជាក់ស្តែង ។

-អប់រំ ផ្សព្វផ្សាយ ដើម្បីលើកកំពស់ផលិតភាព និងប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋ ដោយផ្អែកលើការស្រាវជ្រាវបច្ចេកទេសជំនាញអភិវឌ្ឍន៍ជនបទ ។

-ធ្វើទំនាក់ទំនង សំរបសំរួល និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងផ្នែកឯកជនដែលមានការពាក់ព័ន្ធ ព្រមទាំងប្រជារាស្ត្រមូលដ្ឋាន ដើម្បីធ្វើការអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព ។

-គ្រប់គ្រង ដឹកនាំ និងទទួលខុសត្រូវក្នុងការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ជនទបចំរុះថ្នាក់គ្រួសារ ភូមិ ឃុំ ដែលរួមមានផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋមអភិវឌ្ឍន៍សហគមន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-ជំរុញការរៀបចំ និងពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទគ្រប់ជាន់ថ្នាក់ ជាពិសេសគណៈកម្មាធិការអភិវឌ្ឍន៍ជនបទនៅថ្នាក់មូលដ្ឋាន ។

## ជំពូក ៤

## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ៦.-ថ្មី**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ទទួលបន្ទុកធ្វើទំនាក់ទំនង សំរបសំរួល និងគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក សម្ភារៈ បរិក្ខារ គណនេយ្យ ហិរញ្ញកិច្ច ផែនការ ស្ថិតិតាមដាន និងវាយតម្លៃសហប្រតិបត្តិការជាតិ និងអន្តរជាតិ ព្រមទាំងការងារបណ្តុះបណ្តាល ស្រាវជ្រាវ និងផ្សព្វផ្សាយ ។ អគ្គ

នាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអាចអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ៥ គឺ :

-នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក

-នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

-នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ

-នាយកដ្ឋានបណ្ដុះបណ្ដាល និងស្រាវជ្រាវ

-នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច ។

**មាត្រា ១១.ថ្មី ( បន្ថែម )**

នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចទទួលបន្ទុក :

-រៀបចំ លើកផែនការអភិវឌ្ឍន៍សហគមន៍ជនជាតិភាគតិច សំរាប់រយៈពេលខ្លី មធ្យមនិងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ ពីជនជាតិភាគតិចនៅតំបន់ភ្នំ ខ្ពង់រាប និងវាលទំនាប ដោយកំណត់អោយបានច្បាស់លាស់អំពីអត្តសញ្ញាណ ប្រពៃណី វប្បធម៌ និងទំនៀមទំលាប់ដែលមានស្រាប់ក្នុងសហគមន៍នីមួយៗក្នុងព្រះរាជាណាចក្រកម្ពុជា ។

-រៀបចំ គ្រោង និងអនុវត្តកម្មវិធី និងគំរោងអភិវឌ្ឍន៍ជនជាតិភាគតិចសំរាប់តំបន់ភ្នំ ខ្ពង់រាប និងវាលទំនាប ទៅតាមលំដាប់អាទិភាពដែលបានកំណត់ ។

-សំរបសំរួល រាល់សកម្មភាពអភិវឌ្ឍន៍ជនជាតិភាគតិចនៅតំបន់ភ្នំ ខ្ពង់រាប និងវាលទំនាបក្នុងព្រះរាជាណាចក្រកម្ពុជា ។

-តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍បូកសរុប នូវរាល់សកម្មភាពអនុវត្តកម្មវិធី និងគំរោងអភិវឌ្ឍន៍ជនជាតិភាគតិច ។

-បណ្ដុះបណ្ដាលដល់មន្ត្រីរាជការគ្រប់ថ្នាក់ និងរៀបចំសិក្ខាសាលា ដោយមានការចូលរួមពីគ្រប់ដៃគូអនុវត្តកម្មវិធី និងគំរោងអភិវឌ្ឍន៍ជនជាតិភាគតិច ដើម្បីជំរុញអោយមានការចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍន៍ជនជាតិភាគតិច នៅតំបន់ភ្នំ ខ្ពង់រាប និងវាលទំនាប ។

-បង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលពត៌មានជាតិ ស្ដីពីកិច្ចការអភិវឌ្ឍន៍តំបន់ភ្នំ និងខ្ពង់រាប ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងប្រទេសជិតខាងដែលកំពុងមានកម្មវិធីអភិវឌ្ឍន៍តំបន់ភ្នំ និងខ្ពង់រាបដូចគ្នា ។

-រៀបចំ និងកែលំអគោលនយោបាយអភិវឌ្ឍន៍ប្រជាពលរដ្ឋតំបន់ភ្នំ និងតំបន់ខ្ពង់រាប ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

-លើកឡើងនូវគោលការណ៍ណែនាំ និងកសាងលក្ខណៈវិនិច្ឆ័យ ស្តីពីការបង្កើតសហគមន៍ជនជាតិភាគតិចសំរាប់តំបន់ភ្នំ ខ្ពង់រាប និងវាលទំនាប ។

## ជំពូក ៥

## អគ្គនាយកដ្ឋានបច្ចេកទេស

### មាត្រា ១២.-ថ្មី (មាត្រា១១ចាស់ )

អគ្គនាយកដ្ឋានបច្ចេកទេសទទួលបន្ទុកធ្វើទំនាក់ទំនង សំរបសំរួល និងគ្រប់គ្រងកម្មវិធីផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍន៍សហគមន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ។ អគ្គនាយកដ្ឋាននេះដឹកនាំដោយអគ្គនាយកមួយរូប ដែលអាចអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋានបច្ចេកទេសមាននាយកដ្ឋានចំណុះចំនួន ៥ ដូចតទៅ :

-នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

-នាយកដ្ឋានថែទាំសុខភាពជនបទ

-នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

-នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

-នាយកដ្ឋានផ្លូវលំជនបទ ។

### មាត្រា ១៣.-ថ្មី (មាត្រា១២ចាស់ )

នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពខ្នាតតូចថ្នាក់គ្រួសារ ភូមិ ឃុំ ប្រព័ន្ធវារីអគ្គិសនីតូចៗ ព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ លើកគំរោង ជួសជុល សាងសង់ និងថែទាំប្រព័ន្ធស្រោចស្រពខ្នាតតូចថ្នាក់គ្រួសារ ភូមិ ឃុំ ប្រព័ន្ធវារីអគ្គិសនីតូចៗ ព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-ត្រួតពិនិត្យគុណភាពទឹកអណ្តូងដែលបានជីករួច មុននឹងដាក់ជូនប្រជាពលរដ្ឋមូលដ្ឋាន ប្រើប្រាស់ ។

-រៀបចំបែបបទដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ និងថែទាំដោយប្រជាជន នូវទឹកស្អាតទឹកប្រើប្រាស់ និងទឹកស្រោចស្រពខ្នាតតូច ព្រមទាំងការរៀបចំសមាគម ឬក្រុមអ្នកប្រើប្រាស់ទឹកនៅជនបទ ។

**មាត្រា ១៤.-ថ្មី (មាត្រា១៣ចាស់ )**

នាយកដ្ឋានថែទាំសុខភាពជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការថែទាំសុខភាពបឋមនៅតាមសហគមន៍ជនបទ សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-បណ្តុះបណ្តាលចំណេះដឹង និងជំនាញផ្នែកថែទាំសុខភាពបឋម និងអនាម័យ ដល់មន្ត្រីរាជការអភិវឌ្ឍន៍ជនបទ និងភ្នាក់ងារសុខភាពស្ម័គ្រចិត្តតាមភូមិ ។

-អប់រំសហគមន៍អំពីការថែទាំសុខភាពបឋម ដែលជាអាទិ៍រួមមាន ការអប់រំអំពីអាហារូបត្ថម្ភ ការគាំពារសុខភាពស្ត្រី ការលូតលាស់របស់កុមារ ការថែទាំសុខភាពផ្លូវចិត្ត និងការការពារជម្ងឺផ្សេងៗ ។

-រៀបចំអនាម័យបរិស្ថានក្នុងភូមិ ដោយជួយឧបត្ថម្ភ និងបំផុសប្រជាជនចូលរួមក្នុងការសាងសង់បង្គន់អនាម័យតាមគ្រួសារ និងទីសាធារណៈ ព្រមទាំងអប់រំអ្នកភូមិអោយសំអាតលំនៅឋាន និងប្រើប្រាស់ទឹកស្អាត ។

**មាត្រា ១៥.-ថ្មី (មាត្រា១៤ចាស់ )**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ទទួលបន្ទុក :

-រៀបចំ លើកផែនការអភិវឌ្ឍន៍សហគមន៍សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ លើកគំរោង ជួសជុល និងសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធជនបទរួមមាន សាលារៀន ភូមិអភិវឌ្ឍន៍ មណ្ឌលសុខភាព ។ ល ។ តាមផែនការដែលបានដាក់ចុះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

-សាងសង់ និងគ្រប់គ្រងមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ ។

-ជំរុញ និងលើកទឹកចិត្តប្រជាជនអោយបង្កើនផលិតកម្មស្បៀងដើម្បីផ្គត់ផ្គង់គ្រួសារ និងទីផ្សារ ។

-បញ្ជូនភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ចុះទៅតាមមូលដ្ឋានជនបទ ដើម្បីធ្វើការអប់រំក្រៅប្រព័ន្ធជូនប្រជាជនអំពីអក្ខរកម្ម ការការពារបរិស្ថាន និងធនធានធម្មជាតិ ព្រមទាំងការលើកទឹកចិត្ត

អោយដាំព្រៃឈើឡើងវិញ ការថែរក្សាប្រពៃណី វប្បធម៌ និងសីលធម៌ ក្នុងការរស់នៅ សិទ្ធិប្រជាពលរដ្ឋ លទ្ធិប្រជាធិបតេយ្យ បច្ចេកវិទ្យាសមស្របក្នុងដំណើរការផលិតកម្ម ការការពារគ្រោះថ្នាក់មីន ។ល ។

-ខិតខំជួយដោះស្រាយដល់ជនផ្លាស់ប្តូរទីលំនៅ ។

-រៀបចំបែបបទក្នុងការបង្កើត ពង្រីក និងពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទ ជាពិសេសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឃុំ ។

**មាត្រា ១៦.-ថ្មី (មាត្រា១៥ចាស់ )**

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទសំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-រៀបចំគោលការណ៍ និងបំផុសប្រជាជនចូលរួម ក្នុងការកសាងធនាគារភូមិ ធនាគារស្រូវ ធនាគារសត្វ ធនាគារសម្ភារៈកសិកម្ម ។

-រៀបចំបែបបទ ដែលពាក់ព័ន្ធនឹងការផ្តល់ទុនជូនប្រជារាស្ត្រខ្ចី ការចងក្រងសមាគមឥណទានផ្សេងៗ ។

-លើកទឹកចិត្តប្រជារាស្ត្រជនបទអំពីការងារសន្សំប្រាក់ តាមរយៈការផ្សព្វផ្សាយ ការរៀបចំក្រុមគណៈកម្មការសន្សំប្រាក់ ការណែនាំពីវិធានការរក្សាការពារមូលនិធិសន្សំប្រាក់ ។

-គ្រប់គ្រង ណែនាំអំពីការរៀបចំបញ្ជីការគណនេយ្យសំរាប់ការងារឥណទានជនបទ ។

-ជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋ សមាគម ឬផ្នែកឯកជនផ្សេងៗ ក្នុងការសាងសង់សហគ្រាស និងសិប្បកម្មតូចតាមនៅជនបទ ។

-ស្វែងយល់ និងខិតខំរកទីផ្សារ ដើម្បីដោះស្រាយចរាចរផលិតផលដោយតម្លៃសមស្រប រួមចំណែកក្នុងការលើកស្ទួយកំរិតជីវភាពរស់នៅរបស់ប្រជាកសិករ និងសិប្បករនៅជនបទ ។

**មាត្រា ១៧.-ថ្មី (បន្ថែម)**

នាយកដ្ឋានផ្លូវលំជនបទទទួលបន្ទុក :

-រៀបចំ លើកផែនការស្តារ និងអភិវឌ្ឍន៍ផ្លូវលំជនបទសំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។

-សិក្សា ស្រាវជ្រាវ លើកគំរោង ជួសជុល សាងសង់ និងថែទាំផ្លូវលំជនបទ ។

-តាមដាន និងវាយតម្លៃការអនុវត្តន៍កម្មវិធីការងារប្រចាំឆ្នាំ ។

-គ្រប់គ្រងផ្លូវលំជនបទទាំងអស់ដែលមានយានយន្តបើកបរតិចជាង ៥០ គ្រឿងក្នុងមួយថ្ងៃ ។

-អនុវត្ត និងវិភាគលើការរាប់ចំនួនចរាចរយានយន្ត និងការធ្វើបញ្ជីសារពើភ័ណ្ឌផ្លូវលំ ។

-រៀបចំ និងកែលំអគោលនយោបាយផ្លូវលំជនបទ ដើម្បីអោយស្របទៅតាម :

+ ជំរើសបច្ចេកវិទ្យា

+ វិធាន និងនីតិវិធីនៃកិច្ចសន្យា

+ ខ្នាតគំរូនៃបរិស្ថាន និងសុវត្ថិភាព

+ តួនាទីបុរស នារី ភាពងាយរងគ្រោះក្នុងសង្គម និងខ្នាតគំរូពលកម្ម

-រៀបចំបែបបទដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ និងការថែទាំផ្លូវលំដោយប្រជារាស្ត្រជនបទ ដើម្បីធានាអោយមានការអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព ។

-បណ្តុះបណ្តាល បំពាក់បំប៉នជំនាញផ្លូវលំ ដល់មន្ត្រីរាជការដែលទទួលខុសត្រូវក្នុងការអនុវត្តន៍ និងត្រួតពិនិត្យលើការអនុវត្តន៍កម្មវិធី និងគំរោងផ្លូវលំ ។

## ជំពូក ៦

## ខុទ្ទកាល័យរដ្ឋមន្ត្រី

### មាត្រា ១៨.-ថ្មី (មាត្រា១៦ចាស់ )

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៧

## អង្គភាពមូលដ្ឋាន

### មាត្រា ១៩.-ថ្មី (មាត្រា១៧ចាស់ )

នៅតាមខេត្ត / ក្រុងនីមួយៗ មានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត / ក្រុងមួយ ដែលទទួលបន្ទុក អនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

## ជំពូក ៨

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២០.-ថ្មី (មាត្រា១៨ចាស់ )**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ៩

## អវសានប្បញ្ញត្តិ

**មាត្រា ២១.-ថ្មី (មាត្រា១៩ចាស់ )**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង នៅរដ្ឋបាលកណ្តាលចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២២.-ថ្មី (មាត្រា២០ចាស់ )**

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ននៃស្ថាប័នដទៃទាំងនោះ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវសហការគ្នាដើម្បីបែងចែកការងារទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះតាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងប្រធានស្ថាប័នទាំងនោះ ។

**មាត្រា ២៣.-ថ្មី (មាត្រា២១ចាស់ )**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៤.-ថ្មី (មាត្រា២២ចាស់ )**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និងរដ្ឋលេខា

ធិ[illegible]ួង ស្ថាប័នដែលមាន[illegible]ពាក់ព័ន្ធ និ[illegible]ក្រុងខេត្ត [illegible]មានភារកិច្ចអនុវត្ត

អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

ហត្ថលេខា និងត្រា

**ឈឹម សៀកឡេង**

===

# អង្គការលេខរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ:
ចុះថ្ងៃទី ខែ ឆ្នាំ២០០១

